**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការខេត្ត**
**សៀមរាប_ឧត្តរមានជ័យ**
សាលក្រម
លេខ ៥៩ ខ ចុះថ្ងៃទី ៣១
ខែ ឧសភា ឆ្នាំ ២០០៦
សំណុំរឿងរដ្ឋប្បវេណី
លេខ ១៦៨ ចុះថ្ងៃទី ២៥
ខែ ឧសភា ឆ្នាំ ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**

**តុលាការខេត្តសៀមរាប_ឧត្តរមានជ័យ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៦ ដោយមានសមាសភាព :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ប្រធានតុលាការខេត្ត

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្ត

ដើម្បីជំនុំជំរះសំណុំរឿងក្តីរដ្ឋប្បវេណីលេខ ១៦៨ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៦ ដែលមានកម្មវត្ថុ **ប្តឹងសុំសិទ្ធិទទួលមរតក** ។

រវាងដើមចោទអ្នកស្រី ហ ឆ អាយុ ៧០ឆ្នាំ ជាតិខ្មែរ របររកស៊ីនៅផ្ទះ ទីលំនៅ ផ្ទះលេខ ២៣៦ ក្រុម ១១ ភូមិតាកុល ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ ហ ឧ (ស) ម្តាយឈ្មោះ ស ឃ (ស) ប្តីឈ្មោះ ស ឆល (ស) មានកូន ០៧នាក់ ។

**ដំណើររឿងមានដូចតទៅ :**

តាមពាក្យបណ្តឹងចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៦ របស់ដើមចោទអ្នកស្រី ហ ឆ បានប្តឹងសុំសិទ្ធិគ្រប់គ្រងចាត់ចែងដី ០២ប្លង់ ស្ថិតនៅភូមិតាកុល ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ អា២-១៨២ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩២ និង លេខអា២-១៨៣ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩២ ជាទ្រព្យសម្បត្តិរួមរវាងខ្លួន និង ប្តីឈ្មោះ ស ឆល ដោយសំអាងហេតុថា ដី ០២ប្លង់ នេះជាទ្រព្យសម្បត្តិរួមរវាងខ្លួន និង ប្តីឈ្មោះ ស ឆល ។ ប៉ុន្តែកាលពីថ្ងៃ ២៨ ខែ កក្កដា ឆ្នាំ ២០០៥ ប្តីខ្លួនបានទទួលមរណៈភាពដោយសារជម្ងឺ ។ ថា ខ្លួន និង ប្តីខ្លួនឈ្មោះ ស ឆល មានកូនជាមួយគ្នា ០៧នាក់ គឺកូនទី១ ឈ្មោះ ស ទណ ភេទស្រី អាយុ ៥៣ឆ្នាំ, កូនទី២ ឈ្មោះ ស ឌ (ហៅ អ៊ិត) ភេទស្រី អាយុ

សាលក្រមនេះចូលជាស្ថាពរចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៦
ដោយពុំមានគូភាគីណាមួយប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។
សៀមរាប,ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៦
ក្រឡាបញ្ជី
[illegible] [redacted]

៤៧ ឆ្នាំ. កូនទី៣ ឈ្មោះ **ស ស** ភេទស្រី. កូនទី៤ ឈ្មោះ **ស ឡ** (ហៅ **ផល**) ភេទប្រុស អាយុ ៣៧ឆ្នាំ កូនទី៥ ឈ្មោះ **ស ល** ភេទប្រុស អាយុ ៣៤ឆ្នាំ. កូនទី៦ ឈ្មោះ **ស មន** (**សោម ឆាច**) ភេទប្រុស និង កូនទី៧ ឈ្មោះ **ស ព** ភេទប្រុស អាយុ ២១ឆ្នាំ ។

ថា មកដល់ពេលនេះ ខ្លួនត្រូវការចាំបាច់ ដើម្បីចាត់ចែងលក់ដូរដី ០២ប្លង់នោះ ដើម្បីផ្គត់ផ្គង់ជីវភាព និង ធ្វើការបែងចែកដល់កូន ។

**<u>នាពេលសវនាការ</u>**

ដើមចោទអ្នកស្រី **ហ ធ** បានឆ្លើយថា ខ្លួនប្តឹងសុំសិទ្ធិគ្រប់គ្រងចាត់ចែងដី ០២ប្លង់ ស្ថិតនៅភូមិតាកុល ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខអា២-១៨២ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩២ និង លេខអា២-១៨៣ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩២ ដោយសំអាងហេតុថា ដី ០២ប្លង់នោះជាទ្រព្យសម្បត្តិរួមរវាងខ្លួន និង ប្តីឈ្មោះ **ស ឆល** ។ ប៉ុន្តែកាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ ប្តីខ្លួនបានទទួលមរណៈភាពដោយសារជម្ងឺ ។

ថា ខ្លួន និង ប្តីមានកូនចំនួន ០៧នាក់ គឺកូនទី១ ឈ្មោះ **ស ខណ** ភេទស្រី អាយុ ៥៣ឆ្នាំ. កូនទី២ ឈ្មោះ **ស ធ** (ហៅ **អ៊ិត**) ភេទស្រី អាយុ ៤៧ឆ្នាំ. កូនទី៣ ឈ្មោះ **ស ស** ភេទស្រី អាយុ ៣៩ឆ្នាំ. កូនទី៤ ឈ្មោះ **ស ឡ** (ហៅ **ផល**) ភេទប្រុស អាយុ ៣៧ឆ្នាំ កូនទី៥ ឈ្មោះ **ស ល** ភេទប្រុស អាយុ ៣៤ឆ្នាំ.កូនទី៦ ឈ្មោះ **ស មន** (**សោម ឆាច**) ភេទប្រុស និង កូនទី៧ ឈ្មោះ **ស ព** ភេទប្រុស អាយុ ២១ឆ្នាំ ។

នៅក្នុងរឿងនេះ ខ្លួនសុំសិទ្ធិគ្រប់គ្រងដីចំនួន ០២ប្លង់នោះ ។

តុលាការអោយក្រឡាបញ្ជីអានកំណត់ហេតុយកចម្លើយឈ្មោះ **ស ខណ**. ឈ្មោះ **ស ធ** (ហៅ **អ៊ិត**) ឈ្មោះ **ស ស**. ឈ្មោះ **ស ឡ** (ហៅ **ផល**). ឈ្មោះ **ស ល**. ឈ្មោះ **ស មន** (**សោម ឆាច**) និង ឈ្មោះ **ស ព** បានឆ្លើយថា ខ្លួនយល់ព្រមប្រគល់សិទ្ធិអោយម្តាយរបស់ខ្លួនគ្រប់គ្រងជាកម្មសិទ្ធិនូវដីចំនួន ០២ប្លង់ស្ថិតនៅភូមិតាកុល ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ អា២/១៨២ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩២ និង លេខ អា២/១៨៣ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

**<u>តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា</u>**

រឿងក្តីនេះជារឿងរដ្ឋប្បវេណី ហើយពេលនេះឃើញថា ក្រុមប្រឹក្សាញាតិបានព្រមព្រៀងគ្នាប្រគល់ឱ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ ។

ហេតុនេះសូមតុលាការពិចារណាសំរេចតាមច្បាប់ ។

-បានស្តាប់ចម្លើយដើមចោទឆ្លើយអោយការណ៍ និង ប្តឹងសុំ

-បានស្តាប់ចម្លើយរបស់ក្រុមប្រឹក្សាញាតិ

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

**<u>តុលាការខេត្តសៀមរាប_ឧត្តរមានជ័យ</u>**

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>យល់ឃើញថា</u>**

-ពាក្យបណ្ដឹងរបស់ដើមចោទ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៦ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-ដី ០២ប្លង់ ស្ថិតនៅភូមិតាកុល ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ អា២-១៨២ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩២ និង លេខអា២-១៨៣ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩២ ជាទ្រព្យសម្បត្តិរួមរវាងអ្នកស្រី **ហ ធ** និង ឈ្មោះ **ស ឆល** ។

-អ្នកស្រី **ហ ធ** និងឈ្មោះ **ស ឆល** មានកូនបង្កើតចំនួន ០៧នាក់ គឺកូនទី១ ឈ្មោះ **ស ទណ** ភេទស្រី អាយុ ៥៣ឆ្នាំ, កូនទី២ ឈ្មោះ **ស ឌ** (ហៅ អ៊ីត) ភេទស្រី អាយុ ៤៧ឆ្នាំ, កូនទី៣ ឈ្មោះ **ស ស** ភេទស្រី អាយុ ៣៩ឆ្នាំ, កូនទី៤ ឈ្មោះ **ស ឡ** (ហៅ ផល) ភេទប្រុស អាយុ ៣៧ឆ្នាំ កូនទី៥ ឈ្មោះ **ស ល** ភេទប្រុស អាយុ ៣៤ឆ្នាំ, កូនទី៦ ឈ្មោះ **ស មន** (ហៅ ឆាវ) ភេទប្រុស និង កូនទី៧ ឈ្មោះ **ស ព** ភេទប្រុស អាយុ ២១ឆ្នាំ ។

-ឈ្មោះ **ស ឆល** បានទទួលមរណៈភាព កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ ។

-កូនទាំង ០៧នាក់បានយល់ព្រមប្រគល់សិទ្ធិអោយអ្នកស្រី **ហ ធ** មានសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិដី ០២ប្លង់ ស្ថិតនៅភូមិតាកុល ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខអា២-១៨២ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩២ និង លេខ អា២-១៨៣ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩២ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## ហេតុដូច្នេះទើបវិនិច្ឆ័យសេចក្ដី

១-ទទួលពាក្យបណ្ដឹងរបស់ដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ដី ០២ប្លង់ ស្ថិតនៅភូមិតាកុល ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ អា២-១៨២ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩២ និង លេខ អា២-១៨៣ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩២ ត្រូវប្រគល់អោយអ្នកស្រី **ហ ធ** គ្រប់គ្រងជាកម្មសិទ្ធិ និង មានសិទ្ធិចាត់ចែងតាមការព្រមព្រៀងរបស់ក្រុមប្រឹក្សាញាតិទាំងអស់ ។

៣-សំរេចអោយដើមចោទបង់ប្រាក់ប្រដាប់ក្ដីគឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វីង ១.៨០០រ០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រ០០ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រ០០ បូករួម ៧.០០០រ០០ ។ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រ០០ ដែលដើមចោទបានបង់ទុករួចហើយ ។

៤-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី បើកផ្លូវឧទ្ធរណ៍កំណត់ ០២ខែគិតពីថ្ងៃនេះតទៅ ។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជំរះ**

[redacted]